៣. ឯកឧត្តម សោម ចិន

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តមដែលមានចែងក្នុងមាត្រា១ ត្រូវអនុវត្ត តាមអនុក្រឹត្យនេះតាមភារកិច្ចរៀង ៗ ខ្លួនចាប់ពីថ្ងៃឡាយព្រះហស្ថលេខានិងចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

## ២. សេចក្ដីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៤

### សេចក្ដីសំរេច លេខ ០២ សសរ

### ស្ដីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួងដោះស្រាយដី នៅស្រុកក្រូចឆ្មារខេត្តកំពង់ចាម និងស្រុកពាមរ៉ក៍ ខេត្តព្រៃវែង

* * *

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- តាមសំណើរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការចំរុះអន្តរក្រសួងដោះស្រាយទំនាស់ដី នៅស្រុកក្រូចឆ្មារខេត្តកំពង់ចាម និង ស្រុកពារាំង ខេត្តព្រៃវែង មានដូចតទៅ ÷

១- ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន

២- ឯកឧត្តម យូ ហុកគ្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សមាជិក

៣- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឬ តំណាង - ដ -

៤- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬ តំណាង - ដ -

៥- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬតំណាង - ដ -

៦- ឯកឧត្តមរដ្ឋលេខាធិការទំនាក់ទំនងសភា ឬ តំណាង - ដ -

៧- លោកតំណាងទីស្តីការគណៈរដ្ឋមន្ត្រី - ដ -

៨- លោកអភិបាលខេត្តកំពង់ចាម - ដ -

៩- លោកអភិបាលខេត្តព្រៃវែង - ដ -

១០- លោកស្នងការនគរបាលខេត្ត - ដ -

១១- លោក ប៉ុល លឹម អនុប្រធានអធិការដ្ឋានក្រសួងមហាផ្ទៃ លេខាធិការ

១២- លោក ឡុង កេសាណា អនុប្រធានការិយាល័យអធិការកិច្ចក្រសួងមហាផ្ទៃ - ដ -

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ចចុះដោះស្រាយផ្ដាច់ករណីទំនាស់ដី នៅស្រុកក្រូចឆ្មារ ខេត្តកំពង់ ចាម និង នៅ ស្រុកពារាំង ខេត្តព្រៃវែង ។

**ប្រការ ៣ :** សមាជិកគណៈកម្មាការនេះ ត្រូវចូលរួមប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធាន ។ គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ដើម្បីសំរួលក្នុង ការងារ ។

**ប្រការ ៤ :** គណៈកម្មការនេះ មានសិទ្ធិចាត់តាំងគណៈកម្មការអចិន្ត្រៃយ៍មួយ នៅខេត្តកំពង់ចាម និង ខេត្ត ព្រៃវែង ដើម្បីអនុវត្តអោយបានជាប់ជាប្រចាំ សំដៅទប់ស្កាត់ និងដោះស្រាយទំនាស់ដី នៃ ខេត្តកំពង់ចាម និង ខេត្តព្រៃវែង ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយសភា និង អស់លោកដូចមានចែង ក្នុងប្រការ ១

ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខា នេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្ថលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

* * *

## III - ការបារបណ្ណាក្រសួង

## ពីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៤

### ប្រកាស លេខ ០០៣ ប្រក.សហវ

### ស្តីពីការគ្រប់គ្រងឃ្លាំងបេឡានៃធនាគារជាតិ

* * *

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាសម្តេច ព្រះនរោត្តម សីហនុ ក្នុង ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង គណៈរដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៩ អ.ន.ក្រ ចុះថ្ងៃទី ២០-៥-៩០ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួង ហិរញ្ញវត្ថុ
- តាមសំណើរបស់លោកប្រធាន ធនាគារជាតិ

**សំរេច**

មាត្រា ១ : ឃ្លាំងបេឡា នៃធនាគារជាតិមានតែមួយគត់ ។ ជារៀងរាល់ថ្ងៃត្រូវមានឃ្លាំងបេឡាចរន្ត